**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# លិខិតចំហ
# សូមគោរពជូន ឯកឧត្តម សាយ សំអាល់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន
# ជាទីគោរពដ៏ខ្ពង់ខ្ពស់

យើងខ្ញុំទាំងអស់គ្នាជាសមាជិកបណ្តាញសហគមន៍ព្រៃឡង់បួនខេត្ត ក្រចេះ ស្ទឹងត្រែង ព្រះវិហារ និងកំពង់ធំ ដែលកំពុងធ្វើការងារស្ម័គ្រចិត្តការពារ ព្រៃការពារដែនជម្រកសត្វព្រៃ ព្រៃឡង់ **មានការសោកស្តាយ និងខកចិត្តបំផុត ចំពោះវិធានការរបស់ក្រសួងបរិស្ថានដែលបានរារាំង ការចុះល្បាត ការប្រារព្ធពិធីប្រពៃណី ការគំរាមចាប់ខ្លួន និងជាពិសេសការប្រើអំពើហិង្សាលើសមាជិកដែលចូលរួមប្រារព្ធពិធីបុណ្យព្រៃឡង់ និងបំបួសដើមឈើ។**

យើងខ្ញុំទាំងអស់គ្នាសូមគោរពជម្រាបជូនឯកឧត្តមរដ្ឋមន្ត្រីមេត្តាជ្រាបថា យើងខ្ញុំបានរួមចំណែកការពារព្រៃឡង់យ៉ាងសកម្មរយៈពេលជាង២០ឆ្នាំ ជាមួយកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ក្នុងបុព្វហេតុការពារធនធានធម្មជាតិ និងការស្តារព្រៃឈើឡើងវិញ **តែគួរឱ្យសោកស្តាយ និងខកចិត្តបំផុត ដែលការខិតខំទាំងនេះមិនត្រូវបានលើកទឹកចិត្ត ហើយបែរជាទទួលបាននូវ ការរាំង ការចោទប្រកាន់ លាបពណ៌ គំរាមកំហែង និងការប្រើហិង្សា**មកលើសមាជិកបណ្តាញសហគមន៍ព្រៃឡង់យើងខ្ញុំទៅវិញ។

យើងខ្ញុំសូមស្នើសុំឱ្យ **ឯកឧត្តមរដ្ឋមន្ត្រី ពន្យល់ពីការប្រើអំពើហិង្សាក្រោមការដឹកនាំបញ្ជាដោយ លោក តុប កក្កដា ប្រធានមន្ទីរបរិស្ថានខេត្តកំពង់ធំ** លើសមាជិកបណ្តាញសហគមន៍ព្រៃឡង់ នៅថ្ងៃទី២២ កុម្ភៈ ត្រង់ចំណុចវាលស្រែពពេល។ **តើយើងខ្ញុំទាំងអស់គ្នា មានទោសកំហុសអ្វីបានជាត្រូវប្រើហិង្សាមកលើសហគមន៍? តើការចូលរួមការពារធនធានធម្មជាតិស្របតាមច្បាប់ ស្របតាមការអំពាវនាវរបស់ឯកឧត្តមរដ្ឋមន្ត្រី និងស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ជាអំពើខុសច្បាប់?**

**ឯកឧត្តមរដ្ឋមន្ត្រី**ជាទីគោរព យើងខ្ញុំសូមជម្រាបហេតុផលជូនឯកឧត្តមជ្រាបថា មូលហេតុដែលយើងខ្ញុំនៅតែបន្តចូលទៅ**ល្បាតការពារព្រៃឈើ ដាំដើមឈើឡើងវិញ និងប្រារព្ធពិធីប្រពៃណីផ្សេងៗ ក្នុងតំបន់ការពារដែនជម្រកសត្វព្រៃ ព្រៃឡង់** ព្រោះ៖

១. យើងខ្ញុំទាំងអស់គ្នា**រស់នៅ និងអាស្រ័យផល មានជំនឿ វប្បធម៌ ទំនៀមទម្លាប់ ប្រពៃណីជាជនជាតិដើមភាគតិចកួយ ដែលពឹងផ្អែកទៅលើព្រៃឈើទាំងនោះ។**

២. ព្រៃការពារដែនជម្រកសត្វព្រៃ ព្រៃឡង់ **នៅមិនទាន់មានការកំណត់ និងបែងចែកតំបន់គ្រប់គ្រងនៅឡើយទេ។ ការចោទប្រកាន់ថា យើងខ្ញុំចូលទៅតំបន់ស្នូលខុសនឹងច្បាប់ស្តីពី តំបន់ការពារធម្មជាតិ ជារឿងមិនសមហេតុផលឡើយ** និង

៣. បើទោះបីជា**មាន ឬមិនទាន់មានការកំណត់ និងបែងចែកតំបន់គ្រប់គ្រងក្តី** ហេតុផលសំខាន់បំផុត ដែលបង្ខំឱ្យយើងខ្ញុំត្រូវតែលះបង់ និងប្រឈមនឹងគ្រោះថ្នាក់ក្នុងកិច្ចការពារព្រៃឡង់គឺ **ការកាប់រានដីព្រៃយកជាកម្មសិទ្ធិច្រើនរយហិកតា និងការកាប់រំលំដើមជ័រច្បោះ/ឈើធំៗជារៀងរាល់ថ្ងៃនៅគ្រប់ខេត្ត** ក្នុងតំបន់ការពារ**ដោយជនអនាធិបតេយ្យ** និង**ក្រុមហ៊ុនស៊ីង បាយអូថេក ដែលគួរឱ្យព្រួយបារម្ភបំផុត** ដែលសកម្មភាពល្មើសទាំងនេះអាចនឹងធ្វើឱ្យព្រៃឡង់បាត់បង់ ប្រសិនបើគ្មានកិច្ចខិតខំប្រឹងប្រែងពីគ្រប់ភាគីពាក់ព័ន្ធចូលរួមការពារទេនោះ។

យើងខ្ញុំក៏សូមជម្រាបជូនឯកឧត្តមរដ្ឋមន្ត្រីផងដែរថា **ការចោទប្រកាន់ផ្សេងទៀតដោយអ្នកនាំពាក្យក្រសួងបរិស្ថាន**មកលើយើងខ្ញុំដែលជាសហគមន៍មូលដ្ឋានដែលកំពុងធ្វើការងារការពារព្រៃឈើ **ថាជាសហគមន៍ខុសច្បាប់ គឺជាការគំរាមកំហែងដែលធ្វើឱ្យយើងខ្ញុំមានការព្រួយបារម្ភយ៉ាងខ្លាំង** ខណៈដែលច្បាប់នានា ក៏ដូចជាការថ្លែងរបស់**សម្តេចក្រឡាហោម**

**ស ខេង ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងឯកឧត្តម ប៊ុន ហ៊ុន រដ្ឋលេខាធិការក្រសួងមហាផ្ទៃ** បានគូស បញ្ជាក់ថា **សហគមន៍មូលដ្ឋាន មិនតម្រូវឱ្យចុះបញ្ជីនៅក្រសួងមហាផ្ទៃ ឬមិនស្ថិតនៅក្រោមច្បាប់ស្តីពី សមាគម និងអង្គការមិនមែនរដ្ឋាភិបាលឡើយ។**

យើងខ្ញុំទាំងអស់គ្នាមានជំនឿជាក់ និងក្តីសង្ឃឹមយ៉ាងមុតមាំបំផុតថា ឯកឧត្តមរដ្ឋមន្ត្រីនឹងពិនិត្យ និងសម្រួលដល់កិច្ចការពារព្រៃឈើក្នុងតំបន់ព្រៃឡង់ ចំពោះបណ្តាញសហគមន៍ព្រៃឡង់ក្នុងការ **ល្បាតការពារព្រៃឈើ ដាំដើមឈើឡើងវិញ និងប្រារព្ធពិធីប្រពៃណីផ្សេងៗនៅពេលខាងមុខជាធម្មតាដូចសព្វមួយដង។** អ្វីដែលបានធ្វើឱ្យយើងខ្ញុំមានជំនឿជាក់ និងក្តីសង្ឃឹមយ៉ាងមុតមាំបំផុតនោះ គឺការសម្រេចដាក់បញ្ចូលខេត្តព្រះវិហារ ចូលក្នុងតំបន់ការពារដែនជម្រកសត្វព្រៃ ព្រៃឡង់ កាលពីឆ្នាំ២០១៦ កិច្ចប្រឹងប្រែងជាច្រើនទៀត និងការសម្រួលឱ្យមានកិច្ចសហការនាពេលកន្លងមក បានបង្ហាញពីសុឆន្ទៈ និងការប្តេជ្ញាចិត្តដ៏ត្រឹមត្រូវរបស់ឯកឧត្តមរដ្ឋមន្ត្រីចំពោះការការពារធនធានធម្មជាតិដែលនៅសេសសល់នៅកម្ពុជា។ ប្រសិនបើគ្មានការសម្រេចដ៏ឆ្លាតវៃបែបនេះ ប្រហែលព្រៃឈើនៅតំបន់ព្រៃឡង់ និងតំបន់ឯទៀតអាចត្រូវបាត់បង់ស្ទើរទាំងស្រុងទៅហើយ។

សេចក្តីគួរពុំគួរ ដូចបានអធិប្បាយជូនខាងលើ សូមឯកឧត្តមរដ្ឋមន្ត្រីមេត្តាជ្រាប និងទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីយើងខ្ញុំជាសមាជិកបណ្តាញសហគមន៍ព្រៃឡង់ទាំងបួនខេត្ត ដោយក្តីអនុគ្រោះ។

**ធ្វើនៅថ្ងៃសុក្រ ៦កើត ខែផល្គុន ឆ្នាំកុរ ឯកស័ក ពុទ្ធសករាជ ២៥៦៣**

ត្រូវនឹងថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២០

**បណ្តាញសហគមន៍ព្រៃឡង់**

លោក ខេង ខូ សមាជិកបណ្តាញសហគមន៍ព្រៃឡង់ខេត្តស្ទឹងត្រែង ០៧១ ៤៥១ ៩៤៦៣
កញ្ញា ឈាង លី សមាជិកបណ្តាញសហគមន៍ព្រៃឡង់ខេត្តស្ទឹងត្រែង ០៧១ ៩៩៩ ៤៤៧៣
លោក កាន់ យ៉ាន សមាជិកបណ្តាញសហគមន៍ព្រៃឡង់ខេត្តស្ទឹងត្រែង ០៩៧ ៨១៧ ៦៩៥៤
លោក ពេជ្រ សារិក សមាជិកបណ្តាញសហគមន៍ព្រៃឡង់ខេត្តស្ទឹងត្រែង ០៩៧ ៩២៣ ៣១៩៩
លោក ស្រី ចី សមាជិកបណ្តាញសហគមន៍ព្រៃឡង់ខេត្តព្រះវិហារ ០៩៩ ៧២២ ១៨៧
លោក យុត សឿម សមាជិកបណ្តាញសហគមន៍ព្រៃឡង់ខេត្តព្រះវិហារ ០១៧ ៦៤០ ០៨៤
លោក ខេម សុឃី សមាជិកបណ្តាញសហគមន៍ព្រៃឡង់ខេត្តព្រះវិហារ ០១១ ៨០២ ០៧០
លោក ហួត ឃីម សមាជិកបណ្តាញសហគមន៍ព្រៃឡង់ខេត្តព្រះវិហារ ០៦១ ២៤០ ១៣០
លោក ឯក សុវណ្ណា សមាជិកបណ្តាញសហគមន៍ព្រៃឡង់ខេត្តក្រចេះ ០១២ ៦៣៧ ៧៤៩
លោក ស្វាយ សុង សមាជិកបណ្តាញសហគមន៍ព្រៃឡង់ក្រចេះ ០៧១ ៤៥១ ៩៤៦៥
លោក សៀវ រិន សមាជិកបណ្តាញសហគមន៍ព្រៃឡង់ក្រចេះ ០៩៧ ៣៦៥ ២៣៤២
លោក វ៉ន ត្រែ សមាជិកបណ្តាញសហគមន៍ព្រៃឡង់ក្រចេះ ០៣១ ២៣២ ១១៥២
លោក ហឿន សុភាព សមាជិកបណ្តាញសហគមន៍ព្រៃឡង់ខេត្តកំពង់ធំ ០១២ ៣៧៣ ៤៤១
លោក ម៉ិញ នី សមាជិកបណ្តាញសហគមន៍ព្រៃឡង់ខេត្តកំពង់ធំ ០៩៦ ៣០០ ២៧៦២
លោក សុខ ប្លោក សមាជិកបណ្តាញសហគមន៍ព្រៃឡង់ខេត្តកំពង់ធំ ០៨៧ ៨០០ ៣១២
លោក វ៉ង់ សាន សមាជិកបណ្តាញសហគមន៍ព្រៃឡង់ខេត្តកំពង់ធំ ០៦៩ ៤៩៥ ៧៨៣

**យើងរួមគ្នាការពារព្រៃឡង់ "ព្រៃឡង់ ជាព្រៃរបស់យើងទាំងអស់គ្នា!"**